ភ្នំពេញ, ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២០

**កិច្ចព្រមព្រៀង**

**ស្តីពី**

**ការព្យួរកិច្ចសន្យាការងាររវាងនិយោជក**

**និងនិយោជិតនៃសណ្ឋាគារកាំបូឌីយ៉ាណាក្រោយរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារ**

**ជំងឺកូវិដ-១៩**

ដោយបានឃើញអំពីទុកលំបាកដែលសណ្ឋាគារកាំបូឌីយ៉ាណា បាននិងកំពុងប្រឈមនាពេលបច្ចុប្បន្ន ដោយសារឥទ្ធិពលនៃការរីកសាយភាយជំងឺសកល កូវីដ-១៩ ដែលបានបណ្តាលឱ្យដំណើរការអាជីវកម្មរបស់សណ្ឋាគារជួបប្រទះនូវវិបត្តិយ៉ាងធ្ងន់ធ្ងរពីមួយថ្ងៃទៅមួយថ្ងៃ ក្នុងនោះចំនួនភ្ញៀវស្នាក់នៅក្នុងសណ្ឋាគារបានបន្តធ្លាក់ចុះរហូតស្មើសូន្យ (0) សិក្ខាសាលានិងកិច្ចប្រជុំនានាត្រូវបានផ្អាកចំនួនបោកគក់ក៏ធ្លាក់ចុះយ៉ាងគំហុក គិតចាប់ពីពាក់កណ្តាល ខែមីនា ឆ្នាំ២០២០ មកទល់បច្ចុប្បន្ន។

ប្រឈមនិងបញ្ហានេះ និងដើម្បីបញ្ចៀសកុំឱ្យមានការផ្អាកដំណើរការអាជីវកម្មទាំងស្រុងរបស់សណ្ឋាគារ យើងខ្ញុំជានិយោជិតទាំងអស់នៃសណ្ឋាគារកាំបូឌីយ៉ាណា យល់ព្រមទទួលយកការកំណត់ព្យួរកិច្ចសន្យាការងាររយៈពេល៦០ថ្ងៃដោយគ្មានប្រាក់ឈ្នួលនិងប្រាក់ឧបត្ថម្ភផ្សេងៗ តាមការកំណត់របស់សណ្ឋាគារ គិតចាប់ពីថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២០ ដល់ថ្ងៃទី៣១ សីហា ឆ្នាំ២០២០ រហូតទាល់តែទទួលបានការជូនដំណឹងជាថ្មី។

ដោយសារផ្នែកខ្លះនៃសណ្ឋាគារត្រូវបានផ្អាក និងខ្លះទៀតនៅមានប្រតិបត្តិការតិចតួចនៅឡើយ ហេតុដូច្នេះចំនួននិយោជិតដែលត្រូវបានព្យួរកិច្ចសន្យាការងារលើសពីរ ២១ថ្ងៃមានចំនួន២២៣នាក់។

ដើម្បីជាសក្ខីភាព យើងខ្ញុំទាំងអស់គ្នាសូមផ្តិតស្នាមម្រាមដៃ និងចុះហត្ថលេខារួមគ្នា។

រាជធានីភ្នំពេញថ្ងៃទី១៧ ខែ មិថុនា ឆ្នាំ២០២០

ហត្ថលេខា និងត្រា

ម្ចាស់ ឬនាយក

តំណាងនិយោជិត

313 Sisowath Quay, Phnom Penh, Kingdom of Cambodia
Tel: 855-23 426 288/218 189 | Fax: 855-23 217 059